ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៦៤៧៥ ព.ណ.ររស

ថ្ងៃ អង្គារ ១៥កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ.អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ដល់៣១ ខែកក្កដា ឆ្នាំ២០១៩ នឹងត្រូវលក់៣.៩១០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៧៣៦រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី១៦ ដល់៣១ ខែកក្កដា ឆ្នាំ២០១៩** នឹងចុះមក៣.៧៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៥៥០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | Average MOPS | ០,៤៥២៣ដុល្លារ | ០,៤៩៣៧ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៧៩១ ដុល្លារ | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | ០,០២៩៦ ដុល្លារ |
| ៣ | PREMIUM | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៨៣១ ដុល្លារ | ០,០៧៩៣ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩១៤៦ ដុល្លារ | ០,៨៧២៦ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.៧៣០ រៀល | ៣.៥៩៩ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩១ ដុល្លារ | ០,៨៧ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.៧៥០ រៀល | ៣.៥៥០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៩ ដែលស្មើនឹង ៤០៧៩រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង DO 0.05% (USD/Barrel) |
|---|---|---|
| ១ កក្កដា ២០១៩ | ៧១,៧០ | ៨០,០១ |
| ២ កក្កដា ២០១៩ | ៧០,៣៧ | ៧៨,៧០ |
| ៣ កក្កដា ២០១៩ | ៦៨,៤០ | ៧៥,៨៧ |
| ៤ កក្កដា ២០១៩ | ៧០,០៨ | ៧៦,៤៩ |
| ៥ កក្កដា ២០១៩ | ៧០,៣៧ | ៧៦,០៩ |
| ៨ កក្កដា ២០១៩ | ៧១,២៥ | ៧៧,៤៧ |
| ៩ កក្កដា ២០១៩ | ៧០,៣២ | ៧៦,៨៧ |
| ១០ កក្កដា ២០១៩ | ៧២,៥០ | ៧៨,៨០ |
| ១១ កក្កដា ២០១៩ | ៧៥,៦៥ | ៨១,៧៤ |
| ១២ កក្កដា ២០១៩ | ៧៦,០១ | ៨០,៩៧ |
| ១៥ កក្កដា ២០១៩ | ៧៤,៤៥ | ៨០,៤៧ |
| មធ្យមភាគ ១១ថ្ងៃ | ៧១,៩១៨២ | ៧៨,៤៩៨២ |
| មធ្យមភាគ (ដុល្លារ/លីត្រ) | ០,៤៥២៣ | ០,៤៩៣៧ |

## ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែមេសា ដល់ ០១ ខែកក្កដា ឆ្នាំ២០១៩




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ ប្រតិបត្តិតាមការចាំបាច់។